# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៩ ស.សរ

## សេចក្តីសំរេច
## ស្តីពីការបង្កើតគណៈកម្មការស្តារ និងប្រមូលយកសំណាត់នាវា និងវត្ថុបុរាណមានតម្លៃនៅក្នុងសមុទ្រ ខេត្តកោះកុង

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការ ដើម្បីស្តារ និងប្រមូលយកសំណាត់នាវា និងវត្ថុបុរាណមានតម្លៃដែលលិចនៅក្នុងសមុទ្រក្នុងដែនដីខេត្តកោះកុងដែលមានសមាសភាពដូចខាងក្រោម ÷

- ឯកឧត្តមនាយឧត្តមសេនីយ៍ ហុក ឡុងឌី អគ្គស្នងការនគរបាលជាតិ ប្រធាន
- ឯកឧត្តម យុទ្ធ ភូថង អភិបាលខេត្តកោះកុង អនុប្រធាន
- ឯកឧត្តម ឃឹម សារិទ្ធ រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- ឯកឧត្តម លី យ៉ុងផាត់ បេសកជនពិសេសរបស់សម្តេចនាយករដ្ឋមន្ត្រី សមាជិក
- ឯកឧត្តម ឆឹម ឿន អគ្គលេខាធិការរងរាជរដ្ឋាភិបាល សមាជិក
- ឧត្តមសេនីយ៍ឯក ចាន់ អិន ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន នៃក្រសួងមហាផ្ទៃ សមាជិក
- ឧត្តមសេនីយ៍ទោ តេង ឈួន មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- ឧត្តមនាវីត្រី កែវមុនី ស៊ីកា បញ្ជាការរងកងទ័ពជើងទឹក សមាជិក

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ច :

- ចុះសិក្សាស្រាវជ្រាវ និងប្រមូលសំណាត់ និងវត្ថុបុរាណមានតម្លៃដែលបានស្ការ និងស្រង់រួចហើយ ព្រមទាំងជំរុញការបន្តស្រង់យកសំណាត់នាវា និងវត្ថុបុរាណមានតម្លៃទាំងអស់ពីបាតសមុទ្រនៃមូលដ្ឋាន ខេត្តកោះកុង ដើម្បីយកមកតម្កល់ទុកជាបណ្តោះអាសន្ន ក្នុងខេត្តកោះកុងរង់ចាំការសំរេចពីរាជរដ្ឋាភិបាល ។
- ធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួនជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** ចំពោះមធ្យោបាយ និងថវិកាសំរាប់ប្រើប្រាស់ក្នុងកិច្ចការនេះ គណៈកម្មការត្រូវសហការជាមួយឯកឧត្តម លី យ៉ុងផាត់ បេសកកជនពិសេសរបស់សម្តេចនាយករដ្ឋមន្ត្រី ។

**ប្រការ ៤ :** សមាជិកគណៈកម្មការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួង- ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០៦*

ហ៊ុន សែន

<u>**កន្លែងទទួល**</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥*
- *ឯកសារ- កាលប្បវត្តិ*